ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

លេខ: ០១៤ សជណ/កសស/រប.ធម

ថ្ងៃ សុក្រ ០៦ ភេទ ខែ ពិសាខ ឆ្នាំ ជូត ទោស័ក ៣.ស ២៥៦៤
ខេត្តព្រះសីហនុ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០២០

សេចក្តីជូនដំណឹង

ស្តីពី

មហាសន្និបាតតាគហ៊ុនិក លើកទី ៣ ឆ្នាំ ២០២០ របស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតប្រភេទ "ខ" និងប្រភេទ "គ" របស់ **កសស** ទាំងអស់មេត្តាជ្រាបថា៖ **កសស** នឹងរៀបចំការប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៣ តាមកាលកំណត់ដូចខាងក្រោម ៖

១. កាលបរិច្ឆេទកំណត់ទុក (Record Date) : **ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០**
២. កាលបរិច្ឆេទនៃការប្រជុំមហាសន្និបាត : **ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០២០**
៣. ទីកន្លែងនៃការប្រជុំមហាសន្និបាត : **សណ្ឋាគារ សុខា ប៊ិច រីសត, ខេត្តព្រះសីហនុ**
៤. របៀបវារៈនៃការប្រជុំមហាសន្និបាតភាគហ៊ុនិក មានដូចខាងក្រោម ៖

- ម៉ោង ០៨:00 : ការចុះវត្តមានអ្នកចូលរួម
- ម៉ោង ០៨:៣០ : គណៈអធិបតី និងភ្ញៀវកិត្តិយសអញ្ជើញដល់
- ម៉ោង ០៩:00 :
  - ក). ប្រកាសសមាសភាពគណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិក-សមាជិកា
  - ខ). គោរពភ្លេងជាតិ
- ម៉ោង ០៩:៣០ :
  - ក). មតិស្វាគមន៍របស់ប្រធានមហាសន្និបាត
  - ខ). របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្ម ឆ្នាំ២០១៩ និងទិសដៅអនុវត្តការងារ ឆ្នាំ២០២០
  - គ). សំណួរ-ចម្លើយ
- ម៉ោង ១១:00 : សម្រាក ១៥នាទី
- ម៉ោង ១១:១៥ : ពិនិត្យ និងអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០១៩
- ម៉ោង ១១:៤៥ : មតិបិទកម្មវិធី

ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិកនាថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០ (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញ តាមរយៈសារអេឡិចត្រូនិកពី ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ **កសស**) ឬ អាចមកទទួលលិខិតអញ្ជើញនៅទីស្នាក់ការរបស់ **កសស** ដែលមានអាសយដ្ឋានស្ថិតនៅតិរវិថីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ រៀងរាល់ម៉ោងធ្វើការ **ចាប់ពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២០ ដល់ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០** ។

Office : 034 933 416; 034 933 511 Pilot : 034 933 507; Fax : 034 933 693
E-mail : pasinfo@pas.gov.kh; spsez@pas.gov.kh
Website: www.pas.gov.kh

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈការជូនដំណឹងខាងលើ សូមភាគហ៊ុនិក មេត្តាបញ្ជាក់ការចូលរួមមហាសន្និបាតលើកទី៣ ជាមួយ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ របស់ **កសស**) ដោយភ្ជាប់មកជាមួយនូវ លេខអត្តសញ្ញាណវិនិយោគិន ឬអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន **ចាប់ពីថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២០ ដល់ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០២០ (០៨:៣០ - ១៦:០០)** នៅរៀងរាល់ថ្ងៃធ្វើការ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក កំពង់ផែស្វយ័តក្រុងព្រះសីហនុ ឬ ធនាគារ អេស៊ីលីដា ភីអិលស៊ី តាមអាសយដ្ឋាន និងព័ត៌មាន ដូចខាងក្រោម ៖

១. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

- អាសយដ្ឋាន: តិរវិថីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន, សង្កាត់លេខ ៣, ក្រុងព្រះសីហនុ, ខេត្តព្រះសីហនុ
- ទូរស័ព្ទ: (៨៥៥) ១០ ៧៨៨ ៨៨០ / ៩៥ ៦៦៨ ៨៩៧ / ១១ ៨១៧ ៨៤៧
- សារអេឡិចត្រូនិច: pasinfo@pas.gov.kh
- គេហទំព័រ: www.pas.gov.kh

២. ធនាគារ អេស៊ីលីដា ភីអិលស៊ី

- អាសយដ្ឋាន: លេខ ៦១, មហាវិថីព្រះមុនីវង្ស, សង្កាត់ស្រះចក, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥) ២៣ ៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ០៥០១៣)
  - **លោក លឹម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - លេខទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣ / ៧៧ ៥៦៧ ៩៣៥
  - សារអេឡិចត្រូនិច: lim.an@acledabank.com.kh , lim.phengan@gmail.com
  - **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - លេខទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - សារអេឡិចត្រូនិច: huot.sophy@acledabank.com.kh
  - **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - លេខទូរស័ព្ទ: (៨៥៥) ៨១ ៦៨៦ ៩៨៨ / ៦១ ២៨៧ ៧៦៦
  - សារអេឡិចត្រូនិច: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
អនុប្រធានទី២ប្រចាំនាយកដ្ឋាន

លូ គឹមឈន់

ចម្លងជូន៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- គណៈកម្មការមូលបត្រកម្ពុជា
- ក្រុមប្រឹក្សាភិបាល កសស
- មន្ត្រីត្រួតពិនិត្យរដ្ឋអម កសស

"ដើម្បីជូនជ្រាប"
- ផ្សារមូលបត្រកម្ពុជា
- ក្រុមហ៊ុនមូលបត្រ

"ដើម្បីជូនផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ